ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់កម្រៃឧបត្ថម្ភក្នុងពេលបណ្តុះបណ្តាល នៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៩ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលវេទនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩២ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីប្រាក់ឧបត្ថម្ភប្រចាំខែជូនគរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រីដែលត្រូវបានជ្រើសរើសនិងទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ មុនពេលទៅបម្រើការងារជាមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នរដ្ឋ ដើម្បីគាំទ្រការសិក្សាក្នុងរយៈពេលបណ្តុះបណ្តាល។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ៖

- គរុសិស្ស និងគរុនិស្សិត ដែលត្រូវបានជ្រើសរើស និងទទួលការបណ្តុះបណ្តាលក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា លើកលែងតែគរុសិស្ស និងគរុនិស្សិតដែលជាអតីតបុគ្គលិកអប់រំ
- សិស្សមន្ត្រីដែលត្រូវបានជ្រើសរើស និងទទួលការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ហើយដែលត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែតាមការសម្រេចរបស់រាជរដ្ឋាភិបាលផ្អែកលើសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

**មាត្រា៣ .-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

១- គរុសិស្ស សំដៅដល់សិស្សដែលបានប្រឡងជាប់ចូលរៀននៅតាមសាលាគរុកោសល្យ តាមប្រព័ន្ធ១២បូក២។

២- គរុនិស្សិត សំដៅដល់សិស្សឬនិស្សិតដែលបានប្រឡងជាប់ចូលរៀននៅតាមសាលាគរុកោសល្យតាមប្រព័ន្ធ១២បូក៤ បរិញ្ញាបូក១ និងបរិញ្ញាបូក២។

៣- សិស្សមន្ត្រី សំដៅដល់សិស្ស និស្សិត ឬមន្ត្រីដែលបានប្រលងជាប់ជាស្ថាពរ ត្រូវបានជ្រើសរើស និងទទួលការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ហើយដែលត្រូវបានផ្តល់ប្រាក់កម្រៃឧបត្ថម្ភប្រចាំខែតាមការសម្រេចរបស់រាជរដ្ឋាភិបាលផ្អែកលើសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងមុខងារសាធារណៈ។

## ជំពូកទី២
## ប្រាក់កម្រៃឧបត្ថម្ភ

**មាត្រា៤ .-**

ការគណនាប្រាក់កម្រៃឧបត្ថម្ភប្រចាំខែ ត្រូវផ្អែកលើបៀវត្សមូលដ្ឋានទាបបំផុតនៃក្របខណ្ឌរបស់គរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រី ហើយគិតជាភាគរយតាមប្រភេទក្របខណ្ឌនោះ។ ប្រាក់កម្រៃឧបត្ថម្ភត្រូវស្មើឬខ្ពស់ជាងក្របខណ្ឌក្រោមបន្ទាប់។

**មាត្រា៥ .-**

ការផ្តល់ប្រាក់កម្រៃឧបត្ថម្ភ ត្រូវបានកំណត់ជាភាគរយទៅតាមប្រភេទក្របខណ្ឌដូចខាងក្រោម៖

- ក្របខណ្ឌ ក ឬក្របខណ្ឌដែលមានកម្រិតប្រហាក់ប្រហែល ៧០ ភាគរយ
- ក្របខណ្ឌ ខ ឬក្របខណ្ឌដែលមានកម្រិតប្រហាក់ប្រហែល ៧៥ ភាគរយ
- ក្របខណ្ឌ គ ឬក្របខណ្ឌដែលមានកម្រិតប្រហាក់ប្រហែល ៨០ ភាគរយ។

## ជំពូកទី៣
## លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ប្រាក់កម្រៃឧបត្ថម្ភ

**មាត្រា៦ .-**

ការផ្តល់ប្រាក់កម្រៃឧបត្ថម្ភប្រចាំខែ ត្រូវអនុវត្តក្នុងពេលដែលគរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រីស្ថិតក្នុងពេលទទួលការបណ្តុះបណ្តាល។

**មាត្រា៧ .-**

គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ត្រូវទទួលបន្ទុកក្នុងការធ្វើផែនការថវិកាប្រចាំឆ្នាំនិងការបើកផ្តល់ប្រាក់កម្រៃឧបត្ថម្ភតាមប្រព័ន្ធធនាគារជូនគរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រីក្នុងរយៈពេលកំពុងបណ្តុះបណ្តាល។

**មាត្រា៨ .-**

គរុសិស្ស គរុនិស្សិត និងសិស្សមន្ត្រីដែលបានទទួលប្រាក់កម្រៃឧបត្ថម្ភនេះ ត្រូវសងថវិកាវិញក្នុងករណីបោះបង់ការបណ្តុះបណ្តាលដោយមូលហេតុផ្សេងៗ លើកលែងតែក្នុងករណីទទួលមរណភាព ឬមានជំងឺធ្ងន់ធ្ងរដែលមិនអាចបន្តការបណ្តុះបណ្តាលបាន។ ការសងនេះមិនត្រូវបានគិតបញ្ចូលប្រាក់ដែលបានចំណាយផ្សេងៗក្រៅពីប្រាក់កម្រៃឧបត្ថម្ភនេះឡើយ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៩ .-**

ប្រាក់កម្រៃឧបត្ថម្ភដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ។

# ជំពូកទី៥

# អវសានប្បញ្ញត្តិ

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមឡាយព្រះហស្តលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**រដ្ឋមន្ត្រី**
**ក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



៤